**នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល**

# ជំងឺផ្តាសាយបក្សី

## HIGHLY PATHOGENIC AVIAN INFLUENZA



**អាសយដ្ឋាន: លេខ ៧៤ មហាវិថី ព្រះមុនីវង្ស**
**សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា**
ទូរស័ព្ទ : (០២៣) ៤២៧ ៥៩០/ ៤២៦ ៩៧០
ទូរសារ : (០២៣) ៤២៦ ៩៧០/ ៤២៦ ១៦១

ម.ព.ឯ.ក AIDOC
Code: 230-010
Date:
Donated by:

# សេចក្តីថ្លែងអំណរគុណ

**ផ្កាសាយបក្សី** ជាជំងឺថ្មីមួយដែលមិនធ្លាប់កើតមានពីមុនមកនៅក្នុងព្រះរាជាណាចក្រកម្ពុជា ការផ្ទុះជំងឺជាលើកដំបូង បានបង្កផលវិបាកយ៉ាងធ្ងន់ធ្ងរដល់អ្នកចិញ្ចឹមបក្សី ដោយសារអត្រាស្លាប់ខ្ពស់នៅក្នុងហ្វូង និង ការកំទេចបក្សី ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ ។ មន្ត្រីបសុពេទ្យក៏បានជួបប្រទះនឹងការលំបាកយ៉ាងខ្លាំង ក្នុងការកំណត់រោគវិនិច្ឆ័យ និង វិធីសាស្ត្រក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺ ដោយហេតុថា ឯកសារដែលពាក់ព័ន្ធទៅនឹងជំងឺផ្កាសាយបក្សីនេះ មានចំនួនតិចតួចបំផុត ដែលអាចរកបាននៅក្នុងព្រះរាជាណាចក្រកម្ពុជា និង គ្មានឯកសារដែលពាក់ព័ន្ធទៅនឹងជំងឺផ្កាសាយបក្សី ត្រូវបានតំកល់ទុកនៅក្នុងបណ្ណាល័យរបស់នាយកដ្ឋានផលិតកម្ម និង បសុព្យាបាល ។

មើលឃើញភាពកង្វះខាតទាំងនេះ នាយកដ្ឋានផលិតកម្ម និង បសុព្យាបាលក៏បានសំរេចចិត្តធ្វើការស្រាវជ្រាវរកឯកសារមួយចំនួនដែលទាក់ទងទៅនឹងជំងឺនេះ មកចងក្រងជាសៀវភៅស្តីពី **"ជំងឺផ្កាសាយបក្សី"** នេះឡើងដើម្បីទុកជាទុនដល់មន្ត្រីបសុពេទ្យ សំរាប់ប្រើប្រាស់ក្នុងមុខវិជ្ជាជីវៈរបស់ខ្លួន ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ដែលបានផ្តល់ឱកាសសំរាប់យើងខ្ញុំក្នុងការរៀបចំចងក្រងសៀវភៅនេះ និង សូមថ្លែងអំណរគុណចំពោះម្ចាស់ឧបត្ថម្ភថវិកាដែលមានរាយនាមដូចខាងក្រោម:

- ធនាគារអភិវឌ្ឍន៍អាស៊ី (ADB)
- អង្គការស្បៀង និង កសិកម្មនៃសហប្រជាជាតិ (FAO)
- មូលនិធិប្រទេសជប៉ុន (JAPAN)
- មូលនិធិអង្គការ AusAID

- មូលនិធិអង្គការ GTZ
- មូលនិធិ FRENCH COOPERATION
- មូលនិធិសាធារណៈរដ្ឋប្រជាមានិតចិន (CHINA)

យើងខ្ញុំទាំងអស់គ្នារង់ចាំទទួលការទិតៀន ស្តាបនាពីសំណាក់មិត្តអ្នកអានគ្រប់មជ្ឈដ្ឋានដោយក្តីសោមនស្សរីករាយ ។

រាល់មតិ យោបល់រិះគន់កែលំអដើម្បីស្ថាបនាទាំងអស់ សូមផ្ញើរមកៈ

**នាយកដ្ឋានផលិតកម្ម និង បសុពេទ្យាបាល**

លេខ ៧៤ មហាវិថីព្រះមុនីវង្ស សង្កាត់វត្តភ្នំ

ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ

ទូរស័ព្ទៈ (៨៥៥-២៣) ៩៩១ ៨៧៨

ទូរសារៈ (៨៥៥-២៣) ៩៩១ ៨៧៨

ព័ត៌មានបន្ទាន់លេខៈ ០១២ ២១៤ ៩៧០

ភ្នំពេញ ថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៤

# មាតិកា


ទំព័រ

និយមន័យ.......................................................... ១

ភ្នាក់ងារបង្កជំងឺ.......................................................... ១

ការរាលដាលនៃជំងឺផ្ដាសាយបក្សី.......................................................... ៣

ការចំលង.......................................................... ៣

រោគសញ្ញា.......................................................... ៤

ការធ្វើរោគវិនិច្ឆ័យ.......................................................... ៦

ការធ្វើរោគវិនិច្ឆ័យប្រៀបធៀប.......................................................... ៧

ការព្យាបាល.......................................................... ៨

វិធានការការពារ.......................................................... ៨

វិធានជីវសុវត្ថិភាព.......................................................... ១០

វិធានការ ការពារនៅពេលដែលមានផ្ទុះជំងឺនៅលើទីផ្សារសត្វរស់.......................................................... ១១

គ្រោះថ្នាក់ចំពោះសុខភាពសាធារណៈ.......................................................... ១១

## និយមន័យ

ផ្តាសាយបក្សី ជាជំងឺឆ្លងដែលបង្កដោយវីរុស និង បង្កជាជំងឺលើសត្វស្លាបគ្រប់ប្រភេទ រួមទាំងមាន់ មាន់បារាំង មាន់ទោ ក្រួច ទា ក្ងាន និង បក្សីផ្សេងទៀត ។ នៅក្នុងវិស័យចិញ្ចឹមសត្វតាមបែបឧស្សាហកម្ម មាន់ពង ជាប្រភេទដែលទទួលការចំលងខ្លាំងជាងគេ ។ សត្វស្លាបដែលរស់នៅជាសេរី អាចមានវីរុសនៃជំងឺផ្តាសាយនៅក្នុងខ្លួន តែពួកវាពុំឈឺទេ ដោយសារមានភាពស៊ាំធម្មជាតិក្នុងខ្លួន ។ ពពួកសត្វព្រៃ-សត្វស្លាបទឹកជាប្រភពមេរោគ និង អាចជាអ្នកនាំមកនូវការចំលងដល់សត្វស្លាបក្នុងស្រុក ។ វីរុសនៃជំងឺផ្តាសាយបក្សីភាគច្រើន ត្រូវបានគេរកឃើញនៅលើសត្វទា ច្រើនជាងប្រភេទសត្វផ្សេងទៀត ។

## ភ្នាក់ងារបង្កជំងឺ

វីរុសផ្តាសាយបក្សីជា RNA វីរុស ក្នុងគ្រួសារ *Orthomyxoviridae* ប្រភេទ *Influenza* ក្រុម (Type) A ពូជបក្សី ។ ដោយផ្អែកលើទំនាក់ទំនងរបស់អង់ទីសែនដែលមានលើស្រោមខាងក្រៅរបស់វីរុសដូចជា: glycoprotein haemagglutinin (H) និង neuraminidase (N) បច្ចុប្បន្ន វីរុសនៃជំងឺផ្តាសាយបក្សី ត្រូវបានបែងចែកជាច្រើនអនុក្រុម ដូចជាអនុក្រុម H ដែលមានពី $H_1$ ដល់ $H_{15}$ និង អនុក្រុម N ពី $N_1$ ដល់ $N_9$ ។ អនុក្រុម $H_5N_2$ បានធ្វើអោយផ្ទុះជំងឺយ៉ាងធ្ងន់ធ្ងរនៅអាមេរិក ឆ្នាំ១៩៨៣-៨៤ និង នៅ Mexico ឆ្នាំ ១៩៩៤ ។ ជាប្រវត្តិសាស្ត្រ អនុក្រុម $H_5$ និង $H_7$ ជាប្រភេទវីរុសដែលមានឥទ្ធិពលខ្លាំងជាងគេ និង បង្កជំងឺជាញឹកញាប់លើបក្សី ។ វីរុសផ្តាសាយ ដែលបង្កជំងឺលើសត្វស្លាប អាចត្រូវបានចែកដោយផ្អែកលើភាពដែលអាចបង្កជំងឺរបស់វា ។ វីរុស ដែលមានភាពបង្កជំងឺខ្លាំងក្លា (HPAI- highly pathogenic avian influenza) អាចបណ្តាលឱ្យអត្រាសត្វស្លាប់រហូតដល់ ៨០-៩០% ជួនកាល ១០០% ។ នៅលើពិភពលោកមានរបាយការណ៍ជាច្រើន ដែលបានបរិយាយអំពីការផ្ទុះជំងឺ ដែលបង្កឡើងដោយវីរុសប្រភេទនេះ នៅលើសត្វស្លាបស្រុក ចាប់តាំងពីឆ្នាំ ១៩៥៩ ។ ករណីធ្ងន់ធ្ងរ កើតមាននៅប្រទេស




*គំនូសបំព្រួញទី ១: រូបផ្គុំទូទៅនៃវីរុសជំងឺផ្តាសាយបក្សី*

អ៊ីតាលី នៅឆ្នាំ ១៩៩៩/២០០០ ដែលមានការផ្ទុះជំងឺ ៤១៣ ដង និង មានសត្វឆ្លងជំងឺ ១៦លានក្បាល ។ ជំងឺផ្តាសាយបក្សីអាចកើតមាននៅលើសត្វស្លាបដោយពុំមានផ្តល់សញ្ញាសំគាល់ណាមួយឡើយ និង ឆ្លងរាលដាលពីទ្រុងមួយទៅទ្រុងមួយទៀតយ៉ាងឆាប់រហ័ស ។ វីរុសផ្តាសាយក្នុងអនុក្រុមខ្លះបង្កជាជំងឺក្នុងសភាពស្រាល (LPAI- low pathogenic avian influenza) ។ រោគសញ្ញានៃជំងឺ អាចមានតិចតួច ឬ គ្មានតឹកតាងអ្វីទាំងអស់ ហើយអត្រាស្លាប់មានកំរិតទាបបំផុត។ ប៉ុន្តែប្រភេទខ្លះនៃពពួក LPAI បន្ទាប់ពីបានជ្រៀតចូលទៅក្នុងខ្លួនបក្សីមួយរយៈមក អាចវិវឌ្ឍន៏ទៅជា HPAI ។ ជួនកាល ការចំលងដោយមេរោគផ្សេងទៀត ឬ លក្ខខណ្ឌបរិស្ថាន អាចជំរុញឱ្យការចំលងដោយប្រភេទ LPAI ក្លាយទៅជាជំងឺដ៏ធ្ងន់ធ្ងរ ។

អុនក្រុម $H_7N_2$ ត្រូវបានគេរកឃើញនៅលើមាន់ស្រែនៅឆ្នាំ ១៩៩៦-៩៧ ។ វាមិនបណ្តាលឱ្យមាន់ឈឺទេ តែវាបង្កគ្រោះថ្នាក់ដ៏ធំទៅលើឧស្សាហកម្មបក្សី ។ រហូតមកទល់ពេលនេះ ភាគច្រើននៃអនុក្រុម $H_5$ និង $H_7$ អាចបង្កអោយមានជំងឺធ្ងន់ធ្ងរ ។ វីរុស មានបរិមាណច្រើននៅក្នុងលាមក និង អាចរស់បានយូរ ។ ក្នុងមួយក្រាមនៃលាមក ដែលផ្ទុកមេរោគអាចបង្កការចំលងទៅបក្សីចំនួន ១០លានក្បាល ។ វីរុសជំងឺផ្តាសាយបក្សី អាចមាននៅលើសំបកស៊ុត ផ្នែកក្រហម និង សនៃស៊ុតបក្សី ។ នៅសីតុណ្ហភាព ៦៥-៧០ អង្សាសេ

វីរុសអាចរស់បានរយៈពេល ២-៥ នាទី ។ វីរុសធន់នឹងសីតុណ្ហភាពត្រជាក់ ហើយអាចរស់បានយ៉ាងយូរក្នុងសូលុយស្យុងអំបិល (NaCl) និង ហ្វេណុល ។ល។

**ការរាលដាលនៃជំងឺផ្តាសាយបក្សី**

ជំងឺផ្តាសាយបក្សីបានកើតមានតាំងតែពីឆ្នាំ ១៨៨០ មកម្ល៉េះ នៅប្រទេស អ៊ីតាលី និង ត្រូវបានរកឃើញថាបង្កឡើងដោយវីរុស នៅឆ្នាំ ១៩០១ ។ នៅឆ្នាំ ១៩៥៥ ទើបមានការកំណត់ប្រភេទរបស់វីរុស និង ត្រូវបានចាត់បញ្ចូលទៅក្នុងប្រភេទ " Influenza Virus Type A" ។ ជំងឺផ្តាសាយបក្សីធ្ងន់ធ្ងរ កើតមាននៅបណ្តាប្រទេសជាច្រើនដូចជា អាមេរិក កាណាដា អៀរឡង់ អូស្ត្រាលី អង់គ្លេស អាហ្វ្រិកខាងត្បូង ស្កុតឡេន អៀរឡង់ មិកស៊ិក ជប៉ុន ចិន កូរ៉េ ប៉ាគីស្ថាន ហុងកុង តៃវ៉ាន់ ឥណ្ឌូនេស៊ី វៀតណាម ឡាវ ថៃឡង់ និង កម្ពុជា ដោយបណ្តាលអោយមានបក្សីឈឺងាប់ និង ត្រូវសំលាប់ជាច្រើនរយ លានក្បាល ។ បច្ចុប្បន្នដោយសារប្រទេសកំពុងអភិវឌ្ឍន៏ មួយចំនួនពុំទាន់មានឧបរណ៏ពិសោធន៏ទំនើប បណ្តាលឱ្យជួបប្រទះនឹងការលំបាក ក្នុងការធ្វើរោគវិនិច្ឆ័យដើម្បីកំណត់ឱ្យបានច្បាស់ថា ជំងឺដែលកំពុងរាតត្បាតនៅលើពពួកសត្វស្លាបក្នុងប្រទេសរបស់ខ្លួននោះ បង្កដោយវីរុសញូវកាស ឬ ដោយវីរុសនៃជំងឺផ្តាសាយបក្សី ។

**ការចំលង**

បក្សីទឹក-ព្រៃ ជាភ្នាក់ងារចំលងវីរុសផ្តាសាយចំបងបំផុត ។ ពួកវា ដើរតួនាទីជាអ្នកផ្ទុកមេរោគ ជាពិសេសនៅក្នុងពោះវៀន និង បញ្ចេញមកក្រៅតាមលាមក ។ ការប៉ះពាល់ផ្ទាល់រវាងបក្សីព្រៃ និង បក្សីស្រុក តាមរយៈការដកដង្ហើម មិនមែនជាករណីចំបងក្នុងការចំលងវីរុសចូលមកកសិដ្ឋានចិញ្ចឹមបក្សីទេ ។ វីរុសនៃជំងឺផ្តាសាយបក្សី ត្រូវបានបញ្ចេញមកតាមរយៈលាមកទៅក្នុងតំបន់មួយ ដែលបន្ទាប់មកវីរុសនោះនឹងឆ្លងរាលដាលទៅកសិដ្ឋានចិញ្ចឹមបក្សីតាមរយៈមធ្យោបាយចំលងជំងឺផ្សេងៗ ក្នុងនោះទឹកដែលមានផ្ទុក

ដោយវីរុស អាចជាកត្តាចំបងក្នុងការចំលងជំងឺ ។

នៅក្នុងកសិដ្ឋានមួយ ជំងឺផ្តាសាយបក្សីត្រូវបានចំលងតាមរយៈការប៉ះផ្ទាល់ជាមួយសត្វដែលមានជំងឺ ការប៉ះផ្ទាល់ជាមួយឧបករណ៍ ដែលប្រឡាក់ប្រឡូសដោយមេរោគ ឬ ការប៉ះផ្ទាល់ជាមួយបុគ្គលិក កម្មករ នៅក្នុងកសិដ្ឋាននោះ ។ ការប្រើប្រាស់ស្នូកចំណី និង ស្នូកទឹកជាមួយគ្នា អាចនាំមកនូវការចំលងជំងឺ ។ មនុស្ស ជាបុព្វហេតុយ៉ាងសំខាន់ក្នុងការបន្សាយជំងឺទៅបក្សីស្រុក ដោយរួមទាំងអ្នកថែរក្សា កសិករ កម្មករ រថយន្តដឹកជញ្ជូន និង អ្នកបើកបរ ដែលចូលមកក្នុងកសិដ្ឋាន ។ ការធ្វើចរាចរបក្សី នឹងបណ្តាលឱ្យមានការសាយភាយជំងឺផ្តាសាយបក្សីទាំងនៅក្នុង និង ចេញទៅក្រៅកសិដ្ឋាន ។

ការសាយភាយជំងឺផ្តាសាយបក្សីពីកសិដ្ឋានមួយទៅកសិដ្ឋានមួយទៀតជាចំបងកើតឡើងតាមរយៈការប្រឡាក់ប្រឡូសជាមួយនឹងលាមកបក្សីដែលមានផ្ទុកមេរោគ ។

## រោគសញ្ញា

សភាពនៃជំងឺផ្តាសាយបក្សី មានលំដាប់ស្រាលរហូតដល់ធ្ងន់ធ្ងរដែលអាចបណ្តាលឱ្យងាប់ ។ ប្រភេទវីរុសខ្លះ បណ្តាលឱ្យបក្សីងាប់យ៉ាងឆាប់រហ័ស ជាពិសេសនៅលើកូនសត្វ ដោយមិនបញ្ចេញជារោគសញ្ញាអ្វីឡើយ ។ រោគសញ្ញា មានលក្ខណៈខុសគ្នាជាខ្លាំងអាស្រ័យទៅនឹងកត្តាជាច្រើនដូចជា អាយុ ប្រភេទសត្វ ការអនុវត្តន៍ការចិញ្ចឹម និង ប្រភេទវីរុសបង្កជំងឺ ។ បន្ទាប់ពីទទួលការចំលង និង បង្ហាញរោគសញ្ញាដំបូងនៃជំងឺ សត្វអាចងាប់ក្នុងរយៈពេលពី ២-១២ថ្ងៃ ។ រោគសញ្ញាសំខាន់ៗ នៃជំងឺផ្តាសាយបក្សីរួម មាន :

- ការកើនឡើងនៃអត្រាសត្វឈឺ និង សត្វស្លាប់ខ្ពស់
- ក្អក ហៀរសំបោរ ពិបាកដកដង្ហើម ហូរទឹកភ្នែក ជួនកាលហូរឈាមតាមច្រមុះ
- ហើមក្បាល ត្របកភ្នែក សិរ ណង់ និង ជើង
- សិរ ណង់ ជើង ប្រែទៅជាពណ៌ស្វាយ



គំនូសបំព្រួញទី ២: ក្បាលជាំពណ៌ស្វាយ



គំនូសបំព្រួញទី ៣: សិរ ណង់ ហើម និង មានពណ៌ខៀវ/ស្វាយ

- សត្វសំកុក បាត់ថាមពល មិនស៊ីចំណី និង មិនផឹកទឹក
- ចំពោះមាន់ពង ការផ្តល់ស៊ុតថយចុះ ឬ បញ្ឈប់ សំបកស៊ុតមានសភាពទន់
- មានអាការៈប្រកាច់មុនពេលងាប់ រោមបះ ស្នាមជាំឈាមនៅជើង និង ពោះ
- រាគរុះ ចាប់ផ្តើមពីពណ៌បៃតងខ្ចី រហូតដល់ពណ៌ស
- សត្វងាប់ភ្លាម១ដោយគ្មានរោគសញ្ញាក្នុងករណីខ្លះ



*គំនូសបំព្រួញទី ៤: ជើងមានស្នាមជាំពណ៌ស្វាយ ហើម និង មានរបកស្រកា*

## ការធ្វើរោគវិនិច្ឆ័យ

ក្រៅពីការត្រួតពិនិត្យលើរោគសញ្ញាខាងក្រៅ និង ពត៌មានពីការរាតត្បាតនៃជំងឺ ជំងឺផ្តាសាយបក្សី អាចត្រូវបានវិភាគនៅមន្ទីរពិសោធន៍ ដោយប្រើប្រាស់នូវបច្ចេកទេសមួយចំនួនដូចជា Haemagglutination inhibition (HI), NA inhibition, ELISA និង Agar gel immuno-diffusion tests (AGID) ។

វត្ថុវិភាគ ដែលយកពីបក្សីងាប់សំរាប់ការវិភាគរួមមាន កាកសំណល់នៅក្នុងពោះវៀន ឬ តំបារពីក្លូអាក់ និង ច្រមុះ ។ វត្ថុវិភាគដូចជា សួត ថង់ខ្យល់ បំពង់ខ្យល់ ពោះវៀន ផាល តំរងនោម ថ្លើម បេះដូង ឈាម និង ខួរក្បាល អាចយកសំរាប់ធ្វើការវិភាគដោយឡែក១ពីគ្នា ឬ បញ្ចូលជាមួយគ្នា ។ វត្ថមានរបស់វីរុស អាចរកឃើញនៅក្នុងសេរ៉ូមនៃសត្វឈឺ បន្ទាប់ពីការលេចចេញនូវរោគសញ្ញា ៥ ថ្ងៃ ។

វត្ថុវិភាគ ដែលយកពីសត្វរស់រួមមាន តំបារពីក្លូអាក់ និង បំពង់ខ្យល់ បើទោះជាតំបារដែលបានមកពីក្លូអាក់ មានមេរោគច្រើនក៏ដោយ ។ ដោយហេតុថា បក្សីតូច១មួយចំនួនមានការលំបាកក្នុងការយកវត្ថុវិភាគដោយតំបារ ការប្រមូលយកលាមកស្រស់ អាចជាជំរើស ។ វត្ថុវិភាគ ជាលិកា និង តំបារ ត្រូវដាក់នៅក្នុង Isotonic Phosphate Buffered Saline (PBS) ដែលមានប៉េហាស (pH) ៧,០-៧,៤ ដោយមានបន្ថែមនូវ អង់ទីប៊ីយូទិក ប៉ុន្តែត្រូវមានកំហាប់ច្រើនជាង ៥ដង សំរាប់វត្ថុវិភាគជាលាមក និង តំបារពីក្លូអាក់ ។ ជាការចាំបាច់ ត្រូវពិនិត្យមើលប៉េហាស (pH) ឡើងវិញឱ្យនៅត្រឹម ៧,០-៧,៤ និង បន្ថែមល្បាយអង់ទីប៊ីយ៉ូទិក ។ លាមក និង ជាលិកា ដែលបានកិនលំអិត គួរត្រូវបានរៀបចំដាក់ក្នុងកំហាប់ល្បាយ ១០-២០% ក្នុងល្បាយអង់ទីប៊ីយ៉ូទិក ។ ល្បាយនេះ គួរយកទៅវិភាគឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានដាក់បណ្ដុះរយៈពេល ១-២ ម៉ោង នៅក្រោមសីតុណ្ហភាពក្នុងបន្ទប់ ។ ប្រសិនជាមិនអាចធ្វើការវិភាគបានភ្លាម១ទេ ត្រូវយកវាទៅទុកនៅទីត្រជាក់ក្រោមសីតុណ្ហភាព ៤អង្សាសេ អាចរក្សាទុកបាន ៣-៤ ថ្ងៃ ។

## ការធ្វើរោគវិនិច្ឆ័យប្រៀបធៀប

ក្នុងសណ្ឋានស្រួចស្រាវ ជំងឺផ្ដាសាយបក្សីត្រូវញែកឱ្យដាច់ពីជំងឺមួយចំនួនដូចជាអាសន្នរោគបក្សី ញូវកាស រលាកបំពង់ខ្យល់ និង រលាកពោះវៀន (លើសត្វទា) ។

នៅក្នុងសណ្ឋានរ៉ាំរ៉ៃ ត្រូវញែកជំងឺនេះចេញពីជំងឺដែលរាតត្បាតលើផ្លូវដង្ហើមមួយចំនួនដូចជា រលាកបំពង់ខ្យល់ រលាកទងសួត ញូវកាស និង មីកូប្លាស្មូស៊ីស ។

## ការព្យាបាល

ពុំមានឱសថបសុពេទ្យណាមានប្រសិទ្ធភាពក្នុងការព្យាបាលជំងឺផ្តាសាយបក្សីទេ។

## វិធានការពារ

អង្គការអន្តរជាតិផ្នែករោគរាតត្បាត និង អង្គការសុខភាពសត្វពិភពលោក បានចាត់បញ្ចូល HPAI ទៅក្នុងប្រភេទជំងឺ "List A" ដោយផ្អែកទៅលើការឆ្លងរាលដាលយ៉ាងឆាប់រហ័ស និង មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ច ។ ច្បាប់នៅសហគមអឺរ៉ុបបានចែងថា រាល់ការសង្ស័យដែលទាក់ទងទៅនឹងជំងឺផ្តាសាយ ត្រូវធ្វើការអង្កេតតាមដាន និង ចាត់នូវវិធានការសមរម្យ នៅពេលដែលមានការបញ្ជាក់ថាមានជំងឺផ្ទុះឡើង ។ ដើម្បីក៏រិតនូវការឆ្លងរាលដាល សត្វស្លាបទាំងអស់ដែលទទួលការចំលង ត្រូវតែសំលាប់ និង កប់ ចោលតាមវិធានការបសុពេទ្យ ។ ចំណីសត្វ ឧបករណ៏ដែលប្រឡាក់ប្រឡូស និង លាមកសត្វ ត្រូវបំផ្លាញចោល ឬ ធ្វើការរំងាប់ មេរោគ ដើម្បីបង្អាក់សកម្មភាពរបស់វីរុស ។

ដើម្បីការពារការឆ្លងរាលដាលបន្តទៅទៀត សមត្ថកិច្ចបសុពេទ្យ ត្រូវបានតំរូវឱ្យមានការពង្រឹងនូវការត្រួតពិនិត្យចលនាសត្វ នៅក្នុងតំបន់ដែលកើតជំងឺ និងបរិវេណជុំវិញទាំងអស់ក្នុងរង្វង់ ១០គម ជុំវិញតំបន់ផ្ទុះជំងឺ ដែលចាត់ទុកថាជាតំបន់ត្រួតពិនិត្យតាមដាន ។ ប្រសិនជាមានការចាំបាច់ វិធានការសំលាប់សត្វឈឺ ត្រូវបានយកមកអនុវត្ត ដោយធ្វើទៅលើកសិដ្ឋានចិញ្ចឹមបក្សីទាំងអស់ដែលនៅជុំវិញ ឬ មានការទាក់ទងយ៉ាងជិតស្និទជាមួយនឹងកសិដ្ឋានដែលផ្ទុះជំងឺ ។ ដូច្នេះប្រទេសនិមួយៗ ត្រូវមានផែនការច្បាស់លាស់ ដែលបញ្ជាក់អំពីវិធានការដ៏សមស្របមួយ ដែលអាចយកមកអនុវត្តបានភ្លាមៗ ។ នៅក៏រិតកសិដ្ឋានវិធានការអនាម័យ ដូចជាការលាងសំអាត និង ការរំងាប់មេរោគចាំបាច់ត្រូវតែមាន ។ ការផ្តល់ដំណឹងពីការផ្ទុះជំងឺ និង ការសហការណ៏គ្នាទៅវិញទៅមកក្នុងមជ្ឈដ្ឋានអ្នកចិញ្ចឹមបក្សីចាំបាច់ត្រូវមាន ហើយវិធានជីវៈសុវត្ថិភាពដ៏តឹងរឹងបំផុតត្រូវបានយកមកអនុវត្តដើម្បីការពារ ការឆ្លងរាលដាលនៃជំងឺ ។



គំនូសបំព្រួញទី ៥: ការកំទេចមាន់នៅក្នុងកសិដ្ឋានដែលមានផ្ទុះជំងឺ



គំនូសបំព្រួញទី ៦: ការបាចកំបោរ និង បាញ់ថ្នាំសំលាប់មេរោគ

## វិធានជីវសុវត្ថិភាព

វិធានការសុវត្ថិភាពជីវសាស្ត្រ នៅតាមកសិដ្ឋានចិញ្ចឹមបក្សីត្រូវពង្រឹង ដើម្បីចៀសវាងការឆ្លងជំងឺមកក្នុងហ្វូងសត្វ តាមរយៈ សំលៀកបំពាក់ សម្ភារៈ ឧបករណ៍ ការបញ្ចូលសត្វពីខាងក្រៅ ទឹក ចំណីអាហារសត្វ មនុស្ស និង រថយន្ត ។ គោលការណ៍សំខាន់ៗនៃវិធានជីវសុវត្ថិភាពរួមមាន ៖

១. ត្រូវធ្វើរបងអោយបានជិត កុំអោយឆ្កែ ឆ្មា មាន់ ទា របស់អ្នកស្រុកចូលបាន និងមានការប៉ះពាល់ជាមួយសត្វស្លាបព្រៃ ។

២. ជៀសវាងកុំអោយអ្នកក្រៅចូលក្នុងកសិដ្ឋាន ត្រូវប្រើសំលៀកបំពាក់ការពារ ផ្លាស់ប្តូរមុននឹងចូល ប្រើស្បែកជើងកវែង និង ទឹកថ្នាំសំលាប់មេរោគ (TH4) នៅមាត់ច្រកចេញចូល ។

៣. មិនអនុញ្ញាតឱ្យកម្មកររស់នៅក្នុងកសិដ្ឋាន ចិញ្ចឹមមាន់ផ្ទាល់ខ្លួនឡើយ ។ ត្រូវមានអនាម័យសំលៀកបំពាក់ ចំពោះអ្នកធ្វើការក្នុងកសិដ្ឋាន និង ត្រូវលាងសំអាតដៃជើង រាល់ពេលចូលក្នុងកសិដ្ឋាន ។

៤. ចំណីអាហារសត្វ ទឹក ត្រូវត្រួតពិនិត្យគុណភាពជាប្រចាំ ។ បើប្រើទឹកត្រពាំង ត្រូវធ្វើការរំងាប់មេរោគដោយប្រើថ្នាំមានជាតិក្លរ (Chlorine) ដាក់ក្នុងអាងទឹក ។

៥. ត្រូវមានការប្រយ័ត្នប្រយែងចំពោះ អ្នកត្រួតពិនិត្យ អ្នកចាក់ថ្នាំ និង អ្នកចិញ្ចឹមសត្វផ្សេងទៀត និង អនុញ្ញាតតែមនុស្ស និង សំភារៈចាំបាច់ចូលក្នុងកសិដ្ឋានតែប៉ុណ្ណោះ ។

៦. ត្រូវមានផែនការចាក់ថ្នាំការពារអោយបានត្រឹមត្រូវ ចំពោះជំងឺ ញូវកាស ហ្គំបូរ៉ូ អាសន្នរោគបក្សី និង វិធានចត្តាឡីស័ក្តដើម្បីការពារជំងឺដែលមានសភាពស្រាល ។

៧. អនុវត្តន៍ វិធានការណ៍យកមាន់ចេញទាំងអស់ និង ចូលទាំងអស់ៈ កាលណាយកមាន់ចេញអស់ ត្រូវតែសំអាតកន្លែងចិញ្ចឹម ជាមួយនឹងសារធាតុដែលមានជាតិសាប៊ូ រួច

ធ្វើការរំងាប់មេរោគដោយប្រើ (TH4) បន្ទាប់មកទុកចោល ១០ ថ្ងៃមុននឹងបញ្ចូលសត្វ ចិញ្ចឹមជាថ្មី ។

៨. ត្រូវលាងសំអាត និង រំងាប់មេរោគដល់សំភារៈប្រើប្រាស់ និង រថយន្ត (កង់ និង ផ្នែកខាងក្រោម) នៅពេលចូល និង ចេញពីកសិដ្ឋាន។

## វិធានការ ការពារនៅពេលដែលមានផ្ទុះជំងឺនៅលើទីផ្សារសត្វរស់

- សំអាតរាល់ឧបករណ៍ យានយន្ត មុននឹងចូលទៅកសិដ្ឋាន
- ទុកសត្វដែលមិនទាន់លក់ ចេញពីសត្វដែលនាំចូលថ្មី
- សំអាត និង ធ្វើការសំលាប់មេរោគនៅកន្លែងលក់ជារៀងរាល់ថ្ងៃ
- កុំបញ្ជូនសត្វដែលនៅសល់ពីការលក់ ទៅកសិដ្ឋានវិញ

## គ្រោះថ្នាក់ចំពោះសុខភាពសាធារណៈ

នៅហុងកុង វីរុសក្នុងអនុក្រុម $H_5N_1$ ដែលបានរកឃើញក្នុងឆ្នាំ ១៩៩៧ បានបង្កជំងឺលើមនុស្សចំនួន ១៨នាក់ ដែលនៅក្នុងនោះ ៦នាក់បានស្លាប់ ។ នៅខែកុម្ភៈ ឆ្នាំ ២០០៣ វីរុសនៅក្នុងអនុក្រុមនេះ ក៏ត្រូវបានរកឃើញផងដែរនៅហុងកុង លើសមាជិកពីររូប ក្នុងគ្រួសារមួយ ហើយម្នាក់ក្នុងចំណោមនោះបានស្លាប់ ហើយសមាជិកផ្សេងទៀតនៅក្នុងគ្រួសារក៏ទទួលការចំលងផងដែរ ។ នាពេលថ្មីៗនេះ នៅប្រទេសវៀតណាម និង ថៃឡង់ដ៏ មានការឆ្លងមកមនុស្សជាច្រើនករណីដោយសាវីរុស $H_5N_1$ ។ ក្នុងនោះប្រទេសវៀតណាម មានមនុស្ស ២២ នាក់ បានទទួលការចំលង និង ១៥ នាក់ បានស្លាប់ ។ រីឯនៅប្រទេសថៃឡង់ដ៏ មានមនុស្សចំនួន ១១ នាក់បានទទួល ការចំលង និង ៨ នាក់បានស្លាប់ ។ ដោយហេតុថា ការចំលងមកមនុស្សជាករណីកំរ តែកសិករត្រូវតែប្រុងប្រយ័ត្នជានិច្ច ។

ក្នុងពេលបច្ចុប្បន្ននេះ មានវីរុសផ្តាសាយបក្សី អនុក្រុមពីរផ្សេងទៀត $H_7N_7$ និង $H_9N_2$ ត្រូវបានរកឃើញថា អាចបង្កជំងឺ លើមនុស្សក្នុងសណ្ឋានផ្សេងៗគ្នា ។

នៅឆ្នាំ ១៩៩៦ នៅប្រទេសអង់គ្លេស ប្រភេទវីរុស $H_7N_7$ មានប្រភពពីសត្វស្លាប ត្រូវបានរកឃើញក្នុងភ្នែករបស់ស្ត្រីម្នាក់ (រលាកភ្នែក) ដែលចិញ្ចឹមទា ។ នៅខែ មិនា ឆ្នាំ ១៩៩៩ វីរុស $H_9N_2$ ត្រូវបានរកឃើញនៅលើក្មេងស្រីពីរនាក់ ដែលជាសះស្បើយពីជំងឺដូចផ្តាសាយ នៅហុងកុង ។ ចំពោះវីរុសប្រភេទនេះ ៥ករណីផ្សេងទៀត ត្រូវបានរកឃើញជាបន្តបន្ទាប់នៅលើមនុស្សនៅក្នុង ប្រទេសចិនដីគោក នាខែ សីហា ឆ្នាំ ១៩៩៨ ។ នៅប្រទេសហូឡង់ ថ្ងៃទី ២៨ ខែ កុម្ភៈ ឆ្នាំ ២០០៣ ត្រូវបានរកឃើញថា វីរុសដែលបង្កជំងឺស្ថិតនៅក្នុងអនុក្រុម $H_7N_7$ ។

ឆ្លងតាមការវិភាគ បានបង្ហាញថាវីរុសទាំងនោះមានប្រភពដើមមកពីបក្សី តែរហូតមកដល់ពេលនេះ ពុំទាន់មានការសិក្សាណាមួយបញ្ជាក់ថា មានការឆ្លងពីមនុស្សទៅមនុស្ស ដោយវីរុសមានប្រភពពីបក្សីនៅឡើយទេ ។

ការឆ្លងពីមាន់ទៅមនុស្សអាចកើតមាន ក្រោមលក្ខខណ្ឌមួយចំនួនដូចជា :

- មានការប៉ះពាល់ដោយផ្ទាល់ ដែលជាញឹកញាប់ ការប៉ះពាល់ជាមួយនឹងសត្វងាប់
- ការរស់នៅជិតកសិដ្ឋាន
- អ្នកដែលមានភាពស៊ាំចុះខ្សោយ កុមារ ស្ត្រីមានផ្ទៃពោះ កសិករ កម្មករធ្វើការក្នុងកសិដ្ឋាន អ្នកបច្ចេកទេសបសុពេទ្យ រងគ្រោះច្រើនជាងគេ ។
- កន្លែងដែលមានវីរុសប្រមូលផ្តុំច្រើន

